ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ:..៥៩៥...សហវ.....

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ ២០១១

**គោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

**កម្មវត្ថុ:** ករណីល័ក្ខខ័ណ្ឌនៃឥណទានសម្បទានជប៉ុន សម្រាប់គម្រោងស្តារឡើងវិញនូវប្រព័ន្ធស្រោចស្រព និងប្រព័ន្ធដោះទឹកនៅតំបន់ខាងលិចទន្លេសាប ។

**យោង :** កំណត់ទូតលេខ 039 AJ/ECO ចុះថ្ងៃទី 0៤ ខែ កុម្ភៈ ឆ្នាំ ២០១១ របស់ស្ថានទូតជប៉ុន ប្រចាំនៅកម្ពុជា ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមឧបនាយករដ្ឋមន្ត្រីមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមិនយល់ទាស់ទេ ចំពោះល័ក្ខខ័ណ្ឌនៃឥណទានសម្បទានជប៉ុន សម្រាប់គម្រោងស្តារឡើងវិញនូវប្រព័ន្ធស្រោចស្រព និងប្រព័ន្ធដោះទឹកនៅតំបន់ខាងលិចទន្លេសាប ដែលមានល័ក្ខខ័ណ្ឌ ដូចខាងក្រោម :

- ទឹកប្រាក់ឥណទាន : ៤.២៦៩ លានយ៉េនជប៉ុន
- អត្រាការប្រាក់ : 0,0១ % ក្នុងមួយឆ្នាំ
- រយៈពេលសង : ៤0 ឆ្នាំ ក្នុងនោះ មានរយៈពេលអនុគ្រោះ ១0 ឆ្នាំ
- ប្រភេទឥណទាន : គ្មានចំណង (General untied)

អាស្រ័យហេតុនេះ សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រីមេត្តាជ្រាប និងមានវិធានការ តាមការគួរ ។

សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រីមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន:**

- ស្ថានទូតជប៉ុន ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh

ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com